ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

## សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
## ស្តីពី
## ករណីវិជ្ជមានកូវីដ១៩ លើបុរសជនជាតិអង់គ្លេសអាយុ៧៣ឆ្នាំ និងស្ត្រីជនជាតិអង់គ្លេសអាយុ៦៩ឆ្នាំ ជាអ្នកដំណើរតាមនាវាទេសចរណ៍ (Viking Cruise Journey) នៅខេត្តកំពង់ចាម នៃព្រះរាជាណាចក្រកម្ពុជា

ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបថា ក្នុងចំណោមអ្នកដំណើរសេសសល់តាមនាវាឈ្មោះ Viking Cruise Journey ដែលបានយកសំណាកសរុបចំនួន ៥៩ នាក់ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០លទ្ធផលពីវិទ្យាស្ថានប៉ាស្ទ័រកម្ពុជានៅវេលាយប់ម៉ោង២១:០០នាទី នៃថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០ វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា បានបង្ហាញថា **បុរសជនជាតិអង់គ្លេសអាយុ ៧៣ ឆ្នាំ** (ជាស្វាមី) និង**ស្ត្រីជនជាតិអង់គ្លេសអាយុ ៦៩ ឆ្នាំ** (ជាភរិយា) **វិជ្ជមានវីរុសកូវីដ១៩។**

ជាសរុបអ្នកដំណើរជាជនជាតិអង់គ្លេស វិជ្ជមានវីរុសកូវីដ១៩ គឺ ចំនួន ៣ នាក់ ក្នុងចំណោមអ្នកដំណើរនិងអ្នកបម្រើការនៅលើនាវាទាំងអស់ចំនួន ៦៤ នាក់។

បច្ចុប្បន្ន មន្ទីរសុខាភិបាលខេត្តកំពង់ចាម បានចាត់ចែងយកបុរសនិងស្ត្រីជនជាតិអង់គ្លេសដែលវិជ្ជមានវីរុសកូវីដទាំងពីរនាក់នោះ មកដាក់នៅបន្ទប់ដាច់ដោយឡែកក្នុងមន្ទីរពេទ្យខេត្តកំពង់ចាមរួចហើយ ដើម្បីព្យាបាល និងតាមដានសុខភាពគាត់។ អ្នកដំណើរផ្សេងទៀតចំនួន ៦១ នាក់ ដែលមានលទ្ធផលតេស្តអវិជ្ជមាន ត្រូវយកមកដាក់ដោយឡែកនៅទីកន្លែងសមរម្យនៅលើគោក ដើម្បីតាមដានសុខភាព។

បុរសនិងស្ត្រីជនជាតិអង់គ្លេស វិជ្ជមានវីរុសកូវីដ១៩ ដែលជាស្វាមីនិងភរិយា ខាងលើនេះ ជាអ្នកដំណើរតាមនាវាឈ្មោះ Viking Cruise Journey ដែលនាវានេះ ត្រូវបានដាក់ឲ្យនៅចត្តាឡីស័កនៅទីសំចតទន្លេនៃទីរួមខេត្តកំពង់ចាម តាំងពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០ ក្នុងរយៈពេល ១៤ ថ្ងៃ។

ក្រុមការងារក្រសួងសុខាភិបាល វិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ និងមន្ទីរសុខាភិបាលខេត្តកំពង់ចាម រួមសហការយ៉ាងជិតស្និតជាមួយអាជ្ញាធរខេត្តកំពង់ចាម អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការជំងឺសហរដ្ឋអាមេរិក វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា និងភាគីពាក់ព័ន្ធកំពុងតែយកចិត្តទុកដាក់ក្នុងការអនុវត្តកិច្ចការងារបន្តទៀត ហើយក្រសួងនឹងបន្តជម្រាបជូនសាធារណជន នូវបច្ចុប្បន្នភាពហេតុការណ៍ថ្មីៗបន្ថែមទៀត ប្រសិនបើមាន។



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០/ ៨៨៤ ៩០៩

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ព្រមទាំងស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុតក្នុងការជួយពិនិត្យសុខភាព ក៏ដូចជាជួយសម្របសម្រួលដល់អ្នកដំណើរតាមនាវាខាងលើនេះទាំងអស់ ហើយក្រសួងនឹងបន្តកិច្ចសហការជាមួយអាជ្ញាធរ ស្ថាប័នពាក់ព័ន្ធជាតិ និងអន្តរជាតិ ជាបន្តទៀត រហូតដល់ប្រតិបត្តិការសុខាភិបាល ត្រូវបានបញ្ចប់។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវឌ្ឍនៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃព្រហស្បតិ៍ ៤រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩